## ៨-១-៤ បុណ្យ បច្ច័យបួន

បុណ្យដែលធ្វើដោយ វេរបច្ច័យ (គ្រឿងអាស្រ័យរបស់បព្វជិត) គ្រប់ទាំងបួនមុខ ប្រគេនព្រះសង្ឃ ហៅថា បុណ្យបច្ច័យ ៤ ។

បច្ច័យ ៤ គឺអ្វីខ្លះ? បច្ច័យ ៤ គឺ ៖

១- គ្រឿងស្លៀកដណ្តប់ គឺស្បង់ ចីពរ សង្ឃាដី អង្ស័ក វត្ថពន្ធ កន្សែងដណ្តប់ កន្សែងជូតមុខ ជាដើម ហៅថា **ចីវរប្បច្ច័យ** ។

២- គ្រឿងឆាន់ គឺ បាយ សម្ល ម្ហូបក្រៀម ម្ហូបស្រស់ អំបិល ត្រីងៀត ត្រីឆ្អើរ ជាដើម ព្រមទាំងគ្រឿងប្រដាប់ សម្រាប់ដាក់ចង្ហាន់ មានស្លាបព្រា ចាន ចានស្រាក់ ថាស ជាដើម ហៅថា **បិណ្ឌបាតប្បច្ច័យ** ។

៣- គ្រឿង ដេក អង្គុយ មាន កន្ទេល ខ្នើយ មុង ឆ័ត្រ ស្បែកជើង កុដិ សាលា វិហារ តុ កៅអី ជាដើម ហៅថា **សេនាសនប្បច្ច័យ** ។

៤- គ្រឿងថ្នាំព្យាបាលជម្ងឺ មានថ្នាំបុក គល្លិកា ក្រមួនកុឡា ប្រេងខ្យល់ តែ ស្ករ ជាដើម ហៅថា **គិលានភេសជ្ជប្បច្ច័យ** ។

ទាយក ដែលធ្វើបុណ្យបច្ច័យ ៤ត្រូវធ្វើគ្រប់ទាំង៤មុខ គឺគប្បីលៃធ្វើតាមសមត្ថភាព របស់ខ្លួន បើអាចធ្វើប៉ុណ្ណាបាន ក៏ធ្វើប៉ុណ្ណោះ ទោះបីតិចតួចត្រូវតែគ្រប់ទាំង ៤ មុខ ដូចរៀបរាប់តទៅនេះ គឺ ៖

-មុខ គ្រឿង ចីវរ សូម្បីតែសាដក ១ ឬ ស្បង់ ១ ក៏បាន ។

-មុខគ្រឿងឆាន់ សូម្បីតែចង្ហាន់១ ចំអែតក៏បាន ។

-មុខគ្រឿងសេនាសនៈ សូម្បីតែ កន្ទេល១ ឬ ខ្នើយ១ ក៏បាន ។

-មុខគ្រឿង ភេសជ្ជៈ សូម្បីតែ ប្រេងខ្យល់ ១ ដប ក៏បាន ។

សូមជ្រាបថា បើធ្វើតូច ក្នុងបច្ច័យមួយៗក៏តិច តែទោះបីតិចក៏គប្បីឲ្យគ្រប់៤មុខ ដូចពោលមកហើយ។ បើអាចធ្វើធំ ហើយ ក្នុងមួយមុខៗ ច្រើនបាន ក៏រឹតតែបានផល ច្រើន។

<u>កាតព្វកិច្ច នៃ បុណ្យបច្ច័យ៤</u>

១- ត្រូវនិមន្តព្រះសង្ឃទុក មុនថ្ងៃបុណ្យ

២- ត្រូវរៀបចំទីសេនាសនៈ និង ទេយ្យទាន

៣- នមស្សការព្រះរតនត្រ័យ សមាទានសីល សូត្រមន្ត

៤- វេរបច្ច័យ ៤ និង ប្រគេនទេយ្យទាន

៥- ឧទ្ទិសផល (យំ កិញ្ចិ... )

៦- ធម្មទេសនា ។

<u>សេក្តីសង្កេត</u>

១-ការរៀបចំសេនាសនៈក្នុងពិធីបុណ្យបច្ច័យ៤ ក៏ដូចក្នុងពិធីបុណ្យសង្ឃទានដែរប្លែក តែទេយ្យទាន គឺពិធីបុណ្យបច្ច័យ៤នេះ បើត្រូវធ្វើបច្ច័យធុនកណ្តាល ហើយបើនិមន្ត លោក ៤ អង្គ (តាមនិយមគេនិមន្តព្រះសង្ឃ៤អង្គ) ត្រូវរៀបចំបច្ច័យនីមួយៗ ៤ប្រដាប់ សម្រាប់ប្រគេនលោក ១ប្រដាប់១អង្គ គឺ :

-មុខ បិណ្ឌបាតបច្ច័យ ឲ្យមាន បាយនិងម្ហូបបង្អែម

-មុខគិលានភេសជ្ជបច្ច័យ ត្រូវចងខ្ចប់ដោយក្រដាសភ្លឺៗ ចងបូរ ជាក្បាច់រំលេចពណ៌ ឲ្យល្អស្អាត ហើយយកទាំង៤ប្រដាប់នោះ ទៅតម្កល់ចំពោះ ព្រះកក្រ្តព្រះសង្ឃទាំង៤អង្គ នៅវេលាចម្រើនព្រះបរិត្ត ។

២-ចំពោះបុណ្យបច្ច័យ ៤ ត្រូវនិមន្តព្រះសង្ឃ ជាសង្ឃ មិនមែននិមន្តជាបុគ្គលទេ ពោលគឺ មិននិមន្តចំពោះតែ អង្គណាមួយ ដោយបញ្ជាក់ព្រះនាមព្រះសង្ឃអង្គនោះទេ ។

៣-គេអាចនិមន្តព្រះសង្ឃមកពីវត្តផ្សេងៗគ្នាក៏បាន ហើយគេអាចនិមន្តព្រះសង្ឃលើសពី ៤អង្គបាន ឬក៏និមន្តព្រះសង្ឃតែមួយអង្គ ក៏បានដែរ ព្រោះសំខាន់ លើបច្ច័យដែលត្រូវមាន ៤ មុខ ។

៤-គ្រឿងប្រដាប់ ៤មុខ បើអាចធ្វើបាន ៤ ប្រដាប់ ក៏ធ្វើទៅ ឬបើគេមានទ្រព្យច្រើនហើយអាចធ្វើបានលើសពី៤ប្រដាប់ក៏អត់ទំនាស់អីដែរ។ បើគ្មានយើងនិមន្តព្រះសង្ឃតែមួយអង្គក៏បានដែរ តែត្រូវនិមន្តជាសង្ឃ មិនមែននិមន្តជាបុគ្គល ទេ ។

៥-បើនិមន្តច្រើនអង្គ ហើយចង្ហាន់មានគ្រប់អង្គតែប្រដាប់មានតែមួយគ្រឿងនោះក៏ហៅថាបច្ច័យ៤ដែរ ព្រោះបច្ច័យ មាន៤មុខរួចទៅហើយ គ្រាន់តែលោកមិនបានមួយអង្គមួយប្រដាប់។ បើលោកគង់នៅក្នុងវត្តតែមួយ លោកអាចចែកគ្នាប្រើប្រាស់បាន តែបើលោកនិមន្តមកពីវត្ត ផ្សេង ៗ គ្នា នោះពិបាកបន្តិច ។

៦-បុណ្យបច្ច័យ ៤ ច្រើនកូនចៅគេធ្វើជូនឪពុក ម្តាយគេ ដើម្បីតបស្នងសងគុណគាត់ទាន់គាត់ នៅមានជីវិតនៅឡើយគេអាចអញ្ជើញភ្ញៀវមក ឲ្យបានកុះករដើម្បីឲ្យ គាត់សប្បាយចិត្ត ។ តែកូនចៅត្រូវជំរាបគាត់ទុកជាមុន មិនត្រូវធ្វើដោយមិនឲ្យគាត់ដឹងជាមុននោះទេ។ បើកូនចៅគេមិនធ្វើឲ្យ យើងធ្វើខ្លួនយើងរៀងៗខ្លួន ដោយការភ្ញាក់រលឹកក៏បានដែរ ៕

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។